# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តកណ្ដាល**

លេខ...៨៨៧.......សជណ

ថ្ងៃព្រហស្បតិ៍ ៧រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

កណ្ដាល,ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០២១

## សេចក្ដីជូនដំណឹង

## ស្ដីពី

## ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

-យោងអនុក្រឹត្យលេខ ៤៦ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាល ស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

-យោងអនុក្រឹត្យលេខ ១២២ អនក្រ/បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្ដីពីការកែសម្រួល មាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ ៤៦ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

រដ្ឋបាលខេត្តកណ្ដាល សូមជូនដំណឹងដល់សាធារណជនព្រមទាំងគ្រប់មន្ទីរ គ្រប់អង្គភាព និង ស្ថាប័ន ឬភ្នាក់ងារហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធនឹងក្បាលដីទាំងអស់ស្ថិតនៅក្នុងតំបន់វិនិច្ឆ័យ ចំនួន០៤ភូមិ គឺ**ភូមិល់ហាច ភូមិអង្គមោស ភូមិរំដេញ និងភូមិបេង ឃុំម្កាក់ ស្រុកអង្គស្នួល** ខេត្តកណ្ដាល ស្ថិតក្នុងភូមិ-ឃុំ ខាងលើឲ្យបានជ្រាបថា ដើម្បីអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យយោងខាងលើ គណៈកម្មការរដ្ឋបាល និងធ្វើការបិទផ្សាយជាសាធារណៈនូវឯកសារសុរិយោដី ដែលរួមមានប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី ដែលក្រុមប្រតិបត្តិកម្មវិធីបានធ្វើការវាស់វែង និងប្រមូលទិន្នន័យកន្លងមក។

ហេតុដូចបានជម្រាបជូនខាងលើសូមសាធារណជន និងអង្គភាពនានាដែលមានពាក់ព័ន្ធ និងដីធ្លីក្នុងតំបន់វិនិច្ឆ័យខាងលើមេត្តាចូលរួមពិនិត្យទិន្នន័យដែលមាននៅក្នុងឯកសារនៃការវិនិច្ឆ័យ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ ឬខុសឆ្គង ដែលត្រូវកែតម្រូវ ឬជំទាស់លើទិន្នន័យទាំងនោះក្នុង រយៈពេល១៥ថ្ងៃ (ដោយរាប់បញ្ចូលទាំងថ្ងៃឈប់សម្រាក) គិតចាប់ពីថ្ងៃទី**២៩ ខែកញ្ញា ឆ្នាំ២០២១** ដល់ថ្ងៃទី**១៣ ខែតុលា ឆ្នាំ២០២១** ជាកំហិតដែលមានទីតាំងនៅ **វត្តទន្លេអុំ ស្ថិតនៅភូមិត្រពាំងឆ្មោត ឃុំម្កាក់ ស្រុកអង្គស្នួល** ខេត្តកណ្ដាល។ ផុតកំណត់រយៈពេលខាងលើគណៈកម្មការរដ្ឋបាលសន្មត់ថាទិន្នន័យដែលបានបើកចំហជូនពិនិត្យជាសាធារណៈនេះមានភាពត្រឹមត្រូវ ហើយមិនអាចជំទាស់ ឬតវ៉ានៅពេលក្រោយទៀតបានឡើយ។

**សូមបញ្ជាក់ថា:** ផុតរយៈពេលកំណត់នៃការបិទផ្សាយជាសាធារណៈនេះ គណៈកម្មការរដ្ឋបាលនឹងធ្វើការបូកសរុប ហើយលើកសំណើផ្ដល់សិទ្ធិលើអចលនវត្ថុទៅរដ្ឋបាលខេត្តកណ្ដាល ដើម្បីពិនិត្យសម្រេចរួចបញ្ជូនអោយរដ្ឋបាលសុរិយោដីចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ជូនអ្នកកាន់កាប់ណាដែលបានបំពេញគ្រប់លក្ខណៈតាមច្បាប់។

គណៈកម្មការរដ្ឋបាល នឹងដាក់ទីតាំងបណ្ដោះអាសន្ននៅកន្លែងបិទផ្សាយដើម្បីរង់ចាំទទួលពិគ្រោះ និងផ្ដល់យោបល់ដល់អ្នកដែលមានសំណូមពរ។

**អភិបាលខេត្ត**

**គង់_សោភ័ណ្ឌ**

**កន្លែងទទួល:**

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី
-គណៈកម្មការរដ្ឋបាល "ដើម្បីជ្រាប"
-មន្ទីរ ដ.ន.ស.ស. ខេត្តកណ្ដាល
-រដ្ឋបាលស្រុកអង្គស្នួល
-ការិយាល័យ ដ.ន.ស.ក. ស្រុកអង្គស្នួល
-សាលាឃុំម្កាក់
-គ្រប់ធនាគារ និងអង្គភាពហិរញ្ញវត្ថុ ( ដើម្បីជ្រាបជាព័ត៌មាន និងជួយផ្សព្វផ្សាយ)
-ឯកសារ-កាលប្បវត្តិ